# ហនុមាន ៖ និមិត្តរូបនៃកងទ័ព

នៅពេលដែលនិយាយដល់ឈ្មោះហនុមានប្រជាជនខ្មែរ តែងនឹកដល់រឿងរាមកេរ្តិ៍ ភ្ជាម ព្រោះហនុមានជាសេនាឯករបស់ព្រះរាមនៅក្នុងរឿងនេះ។ ហនុមាន ជាតួអង្គស្វា មានសម្បុរស មានសមត្ថភាពយ៉ាងពិសេស ជាតួអង្គមានកម្លាំងខ្លាំងក្លា មានឫទ្ធិអំណាច អាចហោះហើរជ្រែកដី អាចប្រែក្រឡាបានតាមចិត្តចង់ ហើយជាពិសេសហនុមានជាសេនាដ៏ស្មោះត្រង់បំផុតចំពោះព្រះរាម **(រូបលេខ១)**។ នៅក្នុងអក្សរសិល្ប៍ឥណ្ឌាបានឱ្យដឹងថា ហនុមានជាបុត្ររបស់ព្រះវាយុ (Vayu) ឬខ្មែរច្រើនស្គាល់ថាព្រះពាយ និងអញ្ជនា (Anjana) ដែលត្រូវបណ្តាសាឱ្យក្លាយសត្វស្វា។[១] ចំពោះនៅក្នុងរឿងរាមកេរ្តិ៍ច្បាប់ភាសាខ្មែរវិញ គេដឹងថាហនុមានកំណើតចេញពីនាងស្វាហាយដែលត្រូវបណ្តាសាឱ្យជាប់គូទនឹងថ្ម និងមានភ្នែកខ្វាក់ទាំងសងខាង។ នាងស្វាហាយរស់បានដោយរំពឹងអាហារដែលមកតាមខ្យល់ប៉ុណ្ណោះ។ ថ្ងៃមួយព្រះពាយបានបក់មកជាមួយនូវកាមតណ្ហារបស់ព្រះឥសូរមកឱ្យនាងស្វាហាយ ទើបធ្វើឱ្យនាងមានគភ៌ហើយកើតបានជាហនុមាន។[២]



*រូបភាពទី១៖ គំនូរហនុមាននៅវត្តព្រះកែវមរកតក្រុងភ្នំពេញ (រូបថត៖ ឡេង ស៊ីវង់)*

[១] Aryan, K.C. 1975: 72-73.

[២] រាមកេរ្តិ៍ពោលដោយតាសយ ២០០០, ១-៧។

អត្ថបទដោយ៖ ឡេង ស៊ីវង់

តាមរយៈរឿងរាមកេរ្តិ៍តួអង្គហនុមានបានក្លាយជានិមិត្តរូប នៃមេទ័ពដ៏មានថ្វីដៃប្រកបដោយភាពអង់អាចក្លាហាន និងឫទ្ធានុភាព។ ជាក់ស្តែងនៅក្នុងឈុតដែលហនុមានទទួលបញ្ជាពីព្រះរាមឱ្យយកព្រះទម្រង់ទៅថ្វាយព្រះនាងសីតានៅក្រុងលង្កា គ្រានោះឯងហនុមានបានឆ្លៀតដុះបំផ្លាញក្រុងលង្កាឱ្យខ្ទេចខ្ទីផងដែរ។ ហនុមានក៏ជាតួអង្គសំខាន់ជួយកម្ចាត់ឧបសគ្គឱ្យកងទ័ពផងដែរ ដូចជានៅត្រង់ឈុតព្រះរាមចងស្ពានទៅក្រុងលង្កាជាដើម។ ហនុមានបានជួយឱ្យការចងស្ពាននោះ បានសម្រេចដោយការចុះទៅបង្ក្រាបពួកមច្ឆាដែលព្យាយាមរុះស្ពាននោះចោល។ វិរៈភាពសំខាន់មួយទៀតរបស់ហនុមាន គឺការជួយសង្គ្រោះកងទ័ពព្រះរាមនៅគ្រាមានអាសន្ន។ ជាស្តែងត្រង់ឈុតមួយដែលនិយាយអំពីកុម្ភការណ៍ធ្វើឱ្យព្រះលក្សណ៍សន្លប់ ហនុមានបានទទួលបញ្ជាឱ្យទៅរកថ្នាំដើម្បីយកមកព្យាបាលព្រះលក្សណ៍។ តែដោយហេតុមិនស្គាល់ថ្នាំហនុមានក៏បានលើភ្នំទាំងមូលមកឱ្យពិភេកតែម្តង។

លើសពីនេះទៅទៀតហនុមានក៏ជានិមិត្តរូបនៃការលើកទឹកចិត្តដល់កងទ័ពនៅក្នុងរឿងមហាមហាភារតៈ ដែលជារឿងនិយាយពីសង្គ្រាមរវាងបងប្អូនផងដែរ។ រឿងនេះកើតឡើងនៅគ្រាដែលបងប្អូនបាណ្ឌវៈធ្វើដំណើរទៅដល់ភ្នំហេមពាន្ត ដោយពេលមួយនោះព្រះនាងទ្រោបទីសព្វព្រះទ័យនឹងផ្កាម្យ៉ាងដែលមានក្លិនក្រអូបចម្លែក ទើបសូមឱ្យភីមជាស្វាមីទៅបេះផ្កានោះមកថ្វាយ។ នៅតាមផ្លូវទៅបេះផ្កានោះភីមបានជួបប្រទះនឹងហនុមានដែលកំពុងតែដេកលក់នៅក្នុងព្រៃ បាំងផ្លូវមិនឱ្យភីមបន្តដំណើរទៅមុខបាន។ ហនុមានបានស្នើឱ្យភីមត្រឡប់ក្រោយវិញ តែភីមនៅតែចចេសនឹងបន្តដំណើរទៅមុខតទៅទៀត។ ដូចនេះហើយហនុមានក៏ល្បងកម្លាំងនឹងភីម ប្រសិនបើភីមលើកកន្ទុយរបស់ខ្លួនចេញពីផ្លូវបាន ភីមអាចបន្តដំណើរទៅមុខទៀតបាន។ តែបើទោះបីជាភីមប្រឹងប្រែងកម្រិតណាក៏មិនអាចលើកកន្ទុយរបស់ហនុមានបានដែរ។ ចុងក្រោយភីមក៏ព្រមទទួលចុះចាញ់ហនុមានព្រមទាំងបានសូមទោសហនុមានចំពោះភាពក្អេងក្អាងរបស់ខ្លួន។ ហនុមានឃើញដូចនេះក៏បានប្រាប់ការពិតដល់ភីមថា ខ្លួនជាបុត្ររបស់ព្រះពាយ និងត្រូវជាបងរបស់ភីម។ ដោយសេចក្តីកោតសរសើរចំពោះភីម ហនុមានបានសន្យានឹងភីមថា នៅពេលចាប់ផ្តើមសង្គ្រាមរវាងបាណ្ឌវៈ និងកោរវៈ ហនុមាននឹងអង្គុយលើទង់ជ័យដែលចងលើរាជរថរបស់អរជូន

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

*ដើម្បីជាការលើកទឹកចិត្តដល់កងទ័ពបាណ្ឌវៈ នឹងដើម្បីធ្វើឱ្យកងទ័ពសត្រូវ គឺពួកកៅរវៈ បាក់បបខ្វបខ្វាច។[៣] ហើយជាលទ្ធផលក្រុមបាណ្ឌវៈបានច្បាំងឈ្នះលើពួកកោរវៈ។*

*សាច់រឿងហនុមាននៅក្នុងរឿងមហាភារតៈនេះ ទំនងជាមានទំនាក់ទំនង ឬមានឥទ្ធិពលមកលើកងទ័ពខ្មែរនៅសម័យអង្គរ។ នៅតាមចម្លាក់ប្រាសាទអង្គរវត្ត និងបាយ័ន្តដែលបង្ហាញពីក្បួនកងទ័ពជាច្រើនក្រុមកំពុងធ្វើដំណើរ គេសង្កេតឃើងនៅមុខក្បួនទ័ពខ្វះមានការកាន់ទង់រូបស្វានាំមុខក្បួន(**រូបលេខ២**)។ ការនាំយករូបស្វាមកដាក់លើទង់នាំមុខក្បួនទ័ពបែបនេះប្រហែលជាទទួលឥទ្ធិពលពីរឿងមហាភារតៈក៏ថាបាន ព្រោះរូបស្វានោះប្រហែលជារូបហនុមានដែលជានិមិត្តរូបនៃការលើទឹកចិត្តកងទ័ព និងក៏ទំនងអាចជានិមិត្តរូបនៃជ័យជំនះនៅក្នុងសមរភូមិផងដែរ។ បច្ចុប្បន្ននេះគេរកឃើញរូបបដិមាស្វាធ្វើពីសំរិទ្ធិសម្រាប់ដាក់លើចុងទង់ផងដែរ (**រូបលេខ៣**)។*



*រូបភាពទី២៖ ចម្លាក់កងទ័ពនៅប្រាសាទបាយ័ន្ត (រូបថត៖ ឡេង ស៊ីវ៉េង)*

[៣] ធន់ ហ៊ិន ២០១០: ៣៥៩-៣៦៩។



*រូបភាពទី៣៖ រូបស្វាធ្វើសំរិទ្ធិមកពីប្រាសាទភ្នំបាយ៉ង់ ស.វទី១២ (រូបថត៖ EFEO)*

បច្ចុប្បន្នសង្គមខ្មែរនៅតែឱ្យតម្លៃហនុមានជានិមិត្តរូបនៃកងទ័ពដដែល ដោយហនុមានបានក្លាយជានិមិត្តរូបនៃក្រសួងការពារជាតិដែលជាស្ថាប័នកងទ័ព នៃព្រះរាជាណាចក្រកម្ពុជា (**រូបលេខ៤**)។ យោងតាមសេចក្តីសម្រេចលេខ១៦ សសរ. ស្តីអំពីរូបសញ្ញាក្រសួងការពារជាតិ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០០ បានពន្យល់និមិត្តរូបរបស់ហនុមានថា ជាតំណាងឱ្យកងយោធពលខេមរភូមិន្ទ ជាមេទ័ព និងជាសេនាទ័ពជើងគោកដ៏មានឫទ្ធិ មានចិត្តភក្តីចំពោះមាតុភូមិ ការពារជាតិ សាសនា និងព្រះមហាក្សត្រ៕

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION




*រូបភាពទី៤៖ រូបសញ្ញាក្រសួងការពារជាតិ (រូបថត៖ ក្រសួងការពារជាតិ)*

## បញ្ជីឯកសារយោង


ធន់ ហ៊ិន.

២០១០: *រឿងមហាភារត.*; ភ្នំពេញ។

តាសយ.

២០០០. *ពមកេរ្តិ៍ពោលដោយតាសយ : ល្ខោនខោលវត្តស្វាយអណ្តែត*, ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

Aryan, K.C.

1975. *Hanuman in art and mythology*, Delhi : Rekha Prakashan.


*អត្ថបទដោយ៖ ឡេង ស៊ីវ៉ន*